# ប្រវត្តិព្រះបាទឧតេន

(ស្តេចចេះមន្តបញ្ចាដំរី)



## ធម្មបទដ្ឋកថា អប្បមាទវគ្គទី ២

## សមាវតីវត្ថុទី ១

# ប្រវត្តិព្រះបាទឧតេន

ក្នុងអតីតកាល ព្រះរាជា ២ ព្រះអង្គ គឺ ក្នុងដែនអល្លកប្បៈ ព្រះរាជាទ្រង់ព្រះនាមថា អល្លកប្បៈ ក្នុងដែនវេឋទីបកៈព្រះរាជាទ្រង់ព្រះនាមថា វេឋទីបកៈ ជាសំឡាញ់នឹងគ្នា តាំងពីវេលាទ្រង់នៅវ័យក្មេង ទ្រង់សិក្សាសិល្បៈក្នុងសំណាក់អាចារ្យជាមួយគ្នា ដោយកាលកន្លងទៅ ព្រះរាជបិតារៀង ៗ ខ្លួនបានលើកស្វេតច្ឆត្រឡើងអភិសេក ទ្រង់ជាព្រះរាជាក្នុងដែន ដែលមានបណ្ដោយ ១០ ៗ យោជន៍ ។ ព្រះរាជា ២ ព្រះអង្គនោះ ស្ដេចមកប្រជុំគ្នាតាមកាលគួរ ទ្រង់ឈរ អង្គុយ ផ្ទុំរួមគ្នា ទតឃើញមហាជនអ្នកកើត និងស្លាប់ ទើបទ្រង់ប្រឹក្សាគ្នាថា ឈ្មោះថា អ្នកតាមបុគ្គលទៅកាន់បរលោករមែងមិនមាន ទីបំផុតសូម្បីសរីរៈរបស់ខ្លួន ក៏តាមទៅមិនបាន ត្រូវលះបង់វត្ថុគ្រប់យ៉ាង ប្រយោជន៍អ្វីដោយការនៅគ្រប់គ្រងផ្ទះរបស់យើង យើងនឹងបួស ដូច្នេះហើយ ទើបទ្រង់ប្រគល់រាជសម្បត្តិឲ្យដល់ព្រះឱរស និងព្រះមហេសី ចេញបួសជាឥសីនៅក្នុងព្រៃហិមវន្តប្រទេស ទ្រង់បានប្រឹក្សាគ្នាថា ពួកយើងលះបង់រាជសម្បត្តិ ហើយចេញបួស មិនមែនអស់ផ្លូវចិញ្ចឹមជីវិតទេ យើងទាំងពីរកាលនៅក្នុងទីជាមួយគ្នាក៏ដូចគ្នានឹងកាលដែលយើងមិនបានបួសនោះឯង ព្រោះដូច្នោះ យើងនឹងបែកគ្នារស់នៅ លោកចូរនៅត្រង់កូនភ្នំនោះ យើងនិងនៅត្រង់កូនភ្នំនេះ តែនឹងរួមគ្នាក្នុងថ្ងៃឧបោសថរាល់កន្លះខែម្ដង ។ គ្រានោះ ឥសីទាំងពីរនោះកើតមានសេចក្ដីត្រិះរិះយ៉ាងនេះថា សូម្បីដូច្នេះ ការស្និទ្ធស្នាលដោយគណៈនឹងមាន

ដល់យើងទាំងឡាយ លោកគប្បីដុតភ្លើងឲ្យឆេះឡើងត្រង់ភ្នំរបស់លោក យើងនឹងដុតភ្លើងឲ្យឆេះឡើងត្រង់ភ្នំរបស់យើង ដោយសញ្ញានោះ យើងក៏នឹងដឹងថា លោកនៅមានជីវិត ។ ឥសីទាំងពីរនោះ ក៏ធ្វើយ៉ាងនេះឯង ។

លុះកាលជាបន្តមក វេឋទីបកតាបសធ្វើកាលកិរិយា កើតជាទេវតាដែលមានស័ក្តិធំ ។ បន្ទាប់ពីនោះ គ្រាដល់កន្លះខែ អល្លកប្បតាបសពេលមើលមិនឃើញភ្លើងក៏ដឹងបានថា សម្លាញ់របស់យើងស្លាប់ហើយ ។ សូម្បីតាបសវេឋទីបកៈក៏ពិចារណាមើលទេវសិរី របស់ខ្លួនក្នុងពេលដែលកើត ពិចារណាដល់កម្មឃើញកិរិយាដែលខ្លួនធ្វើ ផ្តើមតាំងពីកាលចេញមកបួស ក៏គិតថា ឥឡូវនេះ យើងនឹងទៅសួរសុខទុក្ខសម្លាញ់របស់យើង ។ ក្នុងខណៈនោះ ទើបក្លែងខ្លួន ធ្វើដូចជាអ្នកវង្វេងផ្លូវ ទៅកាន់សំណាក់របស់អល្លកប្បតាបសនោះ បានថ្វាយបង្គំហើយ ឈរនៅក្នុងទីដ៏សមគួរមួយ ។ លំដាប់នោះ អល្លកប្ប-តាបសនោះ ទើបសួរបុរសនោះថា អ្នកមកអំពីទីណា ។

**បុរស** : លោកម្ចាស់ដ៏ចម្រើន ខ្ញុំជាអ្នកវង្វេងផ្លូវ ដើរមកអំពីទីឆ្ងាយ លោកម្ចាស់នៅតែម្នាក់ឯងប៉ុណ្ណោះក្នុងទីនេះ ឬមានអ្នកដទៃដែរ ?

**អល្លកប្បៈ** : មានសម្លាញ់របស់យើងម្នាក់ទៀត ។

**បុរស** : អ្នកនោះនៅទីណា ?

**អល្លកប្បៈ** : គេនៅត្រង់កូនភ្នំនោះ តែក្នុងថ្ងៃឧបោសថ មិនឃើញគេដុតភ្លើងឲ្យជាសញ្ញា គេប្រាកដជាស្លាប់ហើយ ។

**បុរស** : *យ៉ាងនោះឬ លោកម្ចាស់ ?*

**អល្លកប្បៈ** : *អ្នកមានអាយុ យ៉ាងនោះឯង ។*

**បុរស** : *ខ្ញុំគឺគេនោះឯង លោកម្ចាស់ ។*

**អល្លកប្បៈ** : *លោកកើតក្នុងទីណា ?*

**បុរស** : *ខ្ញុំកើតជាទេវតាដែលមានស័ក្តិធំក្នុងទេវលោក ខ្ញុំមកទីនេះទៀតក៏ដោយបំណងថា នឹងសួរសុខទុក្ខលោកម្ចាស់ តើលោកម្ចាស់នៅទីនេះឧបទ្ទវៈអ្វីខ្លះមានដែរឬ ?*

**អល្លកប្បៈ** : *អាវុសោ យើងលំបាក ព្រោះអាស្រ័យដំរី ។*

**បុរស** : *លោកម្ចាស់ដ៏ចម្រើន ក៏ដំរីធ្វើអ្វីដល់លោក ?*

**អល្លកប្បៈ** : *ដំរីវាបន្ទោបង់លាមកក្នុងទីយើងបោសសម្អាត ហើយយកជើងជាក់កកាយធូលីឡើង ខ្ញុំជញ្ជូនលាមកដំរីទាំងនោះចោល កាយពង្រាបដីឲ្យស្មើ រមែងលំបាក ។*

**បុរស** : *លោកម្ចាស់ប្រាថ្នាមិនឲ្យដំរីទាំងនោះមកទៀតទេ ?*

**អល្លកប្បៈ** : *អើ ! អាវុសោ យើងត្រូវការ ។*

*បុរសពោលថា បើដូច្នោះ ខ្ញុំនឹងធ្វើមិនឲ្យដំរីទាំងនោះមក បានថ្វាយពិណសម្រាប់ឲ្យដំរីស្រឡាញ់ នឹងបង្រៀនមន្តសម្រាប់ឲ្យដំរីស្រឡាញ់ ។ ដល់តាបស*

ក៏កាលនឹងឲ្យ បានប្រាប់ខ្សែពិណា ៣ ខ្សែ ឲ្យរៀនមន្ត ៣ បទ ហើយប្រាប់ថា កាលដេញខ្សែពិណានេះ រាយមន្តបទនេះហើយ ដំរីមិនអាចនឹងបែរមើលក្រោយ រមែងរត់ចេញទៅ, កាលដេញខ្សែពិណានេះ រាយមន្តបទនេះដំរីនឹងត្រឡប់មើលមកខាងក្រោយ ហើយរត់ចេញទៅ, កាលដេញខ្សែពិណានេះ រាយមន្តដោយបទនេះហើយ ដំរីមេហ្វូងរមែងបង្អោនខ្នងចូលមករក ហើយពោលទៀតថា វត្ថុណាដែលលោកពេញចិត្ត លោកគប្បីធ្វើវត្ថុនោះចុះ ។ បុរសនោះសំពះតាបសហើយ ក៏ចៀសចេញទៅ ។ តាបសរាយបទមន្តសម្រាប់ដេញដំរី ដេញខ្សែពិណាសម្រាប់ដេញដំរី ញ៉ាំងដំរីឲ្យគេចចេញទៅ ។

## ព្រះបាទឧតេននិងបក្សីហត្ថិលិង្គ

ក្នុងសម័យនោះ ព្រះរាជាព្រះនាមថា បូរន្តប្បៈ ជាព្រះរាជាក្នុងនគរកោសម្ពី ។ ថ្ងៃមួយ ព្រះបាទបូរន្តប្បៈទ្រង់អង្គុយកម្តៅភ្លើង នៅត្រង់ទីវាលជាមួយព្រះទេវីដែលទ្រង់គភ៌ ។ ព្រះរាជទេវីទ្រង់ដណ្តប់សំពត់កម្ពលក្រហមមានតម្លៃមួយសែន ដែលជាព្រះពស្ត្រសម្រាប់ដណ្តប់របស់ព្រះរាជា ទ្រង់អង្គុយប្រាស្រ័យជាមួយព្រះរាជា ព្រះរាជបានដោះព្រះទម្រង់ ដែលមានតម្លៃមួយសែនអំពីព្រះអង្គុលីរបស់ព្រះអង្គ មកពាក់ត្រង់ម្រាម់ដៃរបស់ព្រះទេវី ។ ក្នុងសម័យនោះ បក្សីហត្ថិលិង្គ ហើរមកតាមផ្លូវអាកាស ឃើញព្រះរាជទេវី ទើបសម្ងបស្ទាបបោះពួយចុះមកដោយសម្គាល់ថា ដុំសាច់ ។ ព្រះរាជាទ្រង់ស្ទុតព្រះទ័យដោយសម្លេងបោះពួយរបស់សត្វនោះ ទើបស្តេចគេចចូលទៅខាងក្នុង

ព្រះរាជនិវេសន៍ ។ ព្រះរាជទេវីមិនអាចទៅដោយរហ័សបាន ព្រោះទ្រង់មានគភ៌ចាស់ផង និងព្រោះជាស្ត្រីមានជាតិជាអ្នកខ្លាចផង ។ គ្រានោះ បក្សីនោះទើបឆាបយកព្រះនាងនោះទុកក្នុងក្រញាំជើង ហើរទៅកាន់អាកាស ។



បក្សីហត្ថិលិង្គឆាបយកព្រះអគ្គមហេសីព្រះបាទបូរន្តប្ប:

បានព្ទថា ពួកបក្សីទាំងនោះ អាចទ្រទ្រង់នូវកម្លាំងនៃដំរីទាំងឡាយ ៥ ព្រោះហេតុនោះ ទើបនាំចំណីទៅតាមផ្លូវអាកាស ទំនៅក្នុងទីដែលខ្លួនពេញចិត្តហើយ រមែងទំពាស៊ីសាច់នោះៗ សម្បីព្រះទេវីនោះ ដែលសត្វនាំទៅទ្រង់ភ័យខ្លាចដល់មរណៈ ទើបទ្រង់ត្រិះរិះថា បើយើងស្រែក ធម្មតាសម្លេងមនុស្សជារបស់គួរខ្លាចនៃពួកសត្វតិរច្ឆាន សត្វនេះឮសម្លេងនោះហើយ នឹងទម្លាក់យើង បើដូច្នោះ យើងនឹងដល់នូវសេចក្តីស្លាប់ ព្រមជាមួយទារកក្នុងគភ៌ ចាំសត្វនេះចុះក្នុងទីណាហើយផ្តើមនឹងស៊ីយើងក្នុងទីនោះ យើងនឹងស្រែកឡើងហើយទះដៃឲ្យវាផ្អើលរត់ចេញ ។ ព្រះនាងក៏នៅស្ងៀមព្រោះភាពជាមនុស្សឆ្លាត ។ ក្នុងកាលនោះ ក្នុងហិមវន្តប្រទេស មានដើមជ្រៃធំមួយដើម ដុះចម្រើនឡើងតិចតួច តាំងនៅដូចជាមណ្ឌប ។ បក្សីនោះនាំចំណីមានម្រឹគជាដើមទៅហើយរមែងស៊ីលើដើមជ្រៃនោះ ព្រោះហេតុនោះ បក្សីហត្ថិលិង្គទើបនាំព្រះរាជទេវីនោះ ទៅត្រង់ដើមជ្រៃនោះឯង ដាក់ទុកក្នុងចន្លោះនៃមែកឈើក្រឡេកមើលផ្លូវដែលខ្លួនហើរមក ។ កាលក្រឡេកមើលផ្លូវហើរមក គឺជារឿងធម្មតារបស់សត្វទាំងនោះ ។ ក្នុងខណៈនោះ ព្រះទេវីទ្រង់ត្រិះរិះថា ឥឡូវនេះគួរដេញសត្វនេះឲ្យរត់ហើយ ទើបទ្រង់លើកព្រះហស្តទាំង ២ ឡើងទះផ្ទប់គ្នាព្រមទាំងស្រែក បង្អើលឲ្យសត្វនោះរត់ចេញទៅ ។ គ្រានោះ ក្នុងវេលាព្រះអាទិត្យអស្តង្គត ខ្យល់កម្មជវាតបក់បោកហើយក្នុងព្រះគភ៌របស់ព្រះទេវីនោះ ។ មហាមេឃកាលបង្អុរចុះ តាំងឡើងក្នុងទិសទាំងពួង ។ ឈ្មោះថា

ការដេកលក់ រមែងមិនមានដល់ព្រះទេវី អស់មួយរាត្រីពេញ ដែលធ្លាប់តែតាំងនៅក្នុងសេចក្តីសុខ មិនបានត្រឹមតែពាក្យពោលថា កុំខ្លាចឡើយព្រះនាងម្ចាស់ចំពោះបុគ្គលដែលមានសេចក្តីទុក្ខគ្រប់សង្កត់ហើយ ។ កាលកន្លងរាត្រីហើយការរាំងនៃវលាហកៈក្តី ការរះឡើងនៃអរុណក្តី ការប្រសូតនៃសត្វដែលនៅក្នុងគភ៌របស់ព្រះនាងក្តី បានមានហើយក្នុងខណៈជាមួយគ្នានោះឯង ។ ព្រះនាងបានតាំងព្រះនាមព្រះឱរសថា **ឧតេន** ព្រោះកាន់យកកាលនៃមេឃកាលនៃគភ៌ និងកាលនៃអរុណ ។

ទីនៅសូម្បីរបស់អល្លកប្បតាបស ក៏នៅមិនឆ្ងាយអំពីដើមជ្រៃនោះ ។ ជាប្រក្រតីក្នុងថ្ងៃមានភ្លៀង តាបសនោះ រមែងមិនទៅកាន់ព្រៃដើម្បី ប្រយោជន៍ដល់ផលាផល ព្រោះខ្លាចរងា បានទៅកាន់គល់ឈើនោះ រើសឆ្អឹងនៃសាច់ដែលសត្វស៊ីហើយ យកមកដំ បានធ្វើនូវរស (ស្ងោរ) ហើយហ៊ុត ។ ព្រោះហេតុនោះ សូម្បីក្នុងថ្ងៃនោះ តាបសក៏គិតថា នឹងរើសឆ្អឹង ទើបទៅកាន់ដើមឈើនោះ ស្វែងរកឆ្អឹងត្រង់គល់ឈើ បានឮសម្លេងក្មេងខាងលើ ទើបក្រឡេកមើលឃើញព្រះទេវី ទើបសួរថា នាងជានរណា ?

**ព្រះទេវី** : ខ្ញុំជាមនុស្សស្រី ។

**តាបស** : នាងមកបានយ៉ាងណា ?

កាលព្រះនាងពោលថា បក្សីហត្ថិលិង្គនាំខ្ញុំមក តាបសក៏ទើបពោលថា នាងចូរចុះមក ។

**ព្រះទេវី** : បពិត្រលោកម្ចាស់ ខ្ញុំខ្លាចដល់ការលោយដោយជាតិ ។

**តាបស** : នាងជានរណា ?

**ព្រះទេវី** : ខ្ញុំជាក្សត្រិយ៍ ។

**តាបស** : សូម្បីយើងក៏ជាក្សត្រដូចគ្នា ។

**ព្រះទេវី** : បើដូច្នោះ លោកចូរសម្ដែងមាយាក្សត្រមកមើល ។

តាបសនោះ ក៏បានសម្ដែងហើយ ។ ព្រះទេវីពោលថា បើដូច្នោះ លោកចូរឡើងមកនាំបុត្ររបស់ខ្ញុំចុះ ។

តាបសនោះក៏ធ្វើផ្លូវឡើងទៅហើយ ទទួលយកទារក កាលព្រះរាជទេវីពោលហាមថា កុំយកដៃប៉ះខ្ញុំ ក៏មិនប៉ះព្រះនាងឡើយ ហើយឱបទារកចុះមក សូម្បីព្រះរាជទេវីក៏ចុះមកដែរ ។ គ្រានោះ តាបសអល្លកប្បៈបាននាំព្រះនាងទៅកាន់អាស្រម ហើយមិនធ្វើនូវសីលភេទឡើយ ទំនុកបម្រុងដោយសេចក្ដីអនុគ្រោះ នាំទឹកឃ្មុំដែលមិនមានកូនមក នាំស្រូវសាលីដែលកើតឯង មកដាំជាយាគូ បានឲ្យហើយ ។ កាលតាបសនោះទំនុកបម្រុងយ៉ាងនោះ ក្នុងកាលដទៃ ព្រះនាងទើបគិតថា យើងមិនស្គាល់ផ្លូវមក និងផ្លូវទៅឡើយ សូម្បីហេតុត្រឹមតែការធ្លាប់ស្គាល់យើងជាមួយតាបសនេះ ក៏មិនមានឡើយ ប្រសិនបើ

តាបសនេះនឹងទុកយើងចោល ទៅណាបាត់ យើងទាំងពីរនាក់ ក៏នឹងដល់សេចក្ដីស្លាប់ក្នុងទីនេះឯង យើងគួរធ្វើឧបាយណាមួយ ទម្លាយសីលរបស់តាបសនេះចេញ ធ្វើដោយអាការៈ ដែលតាបសរូបនេះ មិនអាចលះបង់យើងបាន ។ ពេលនោះ ព្រះនាងទេវីទើបប្រឡោមលួងលោមតាបស ដោយការសម្ដែង (ធ្វើឲ្យ) សំពត់ស្លៀកសំពត់ដណ្ដប់របូត បានដល់នូវការវិនាសនៃសីលហើយ ។ តាំងពីថ្ងៃនោះមក ជនទាំងពីរក៏នៅសមគ្គសង្វាស (ជាស្វាមីភរិយា) ជាមួយគ្នាទៅ ។

ក្នុងថ្ងៃមួយ តាបសត្រួតមើលការប្រកបនៃផ្កាយនក្ខត្តឫក្ស ឃើញការស្រអាប់នៃផ្កាយនក្ខត្តឫក្ស របស់ព្រះបាទបូរន្តប្បៈ ទើបពោលថា ម្នាលនាងដ៏ចម្រើន ព្រះបាទបូរន្តប្បៈក្នុងក្រុងកោសម្ពីចូលទិវង្គតហើយ ។

ព្រះទេវីពោលថា បពិត្រលោកម្ចាស់ ហេតុអ្វី លោកម្ចាស់ទើបពោលយ៉ាងនេះ លោកម្ចាស់មានសេចក្ដីអាឃាតជាមួយព្រះបាទបូរន្តប្បៈនោះឬ ?

តាបសពោលថា ម្នាលនាងដ៏ចម្រើន មិនមានទេ យើងឃើញសេចក្ដីសៅហ្មងនៃផ្កាយនក្ខត្តឫក្សរបស់ព្រះបាទបូរន្តប្បៈ ទើបនិយាយយ៉ាងនេះ ។

ព្រះរាជទេវីក៏ទ្រង់ព្រះកន្សែង ។ គ្រានោះ តាបសអល្លកប្បៈទើបសួរព្រះទេវីនោះថា ព្រោះហេតុអ្វី បានជានាងយំ ?

កាលព្រះរាជទេវីត្រាស់ប្រាប់សេចក្តី ដែលព្រះបាទបូរន្តប្បៈនោះ ជាព្រះស្វាមីរបស់ព្រះនាងហើយ ទើបពោលថា កុំយំអី នាងដ៏ចម្រើន ធម្មតាសត្វដែលកើតហើយ រមែងស្លាប់ដោយពិត ។

ព្រះរាជទេវីពោលថា បពិត្រលោកម្ចាស់ នាងខ្ញុំដឹង ។

លំដាប់នោះ តាបសពោលថា បើដូច្នេះ ហេតុអ្វីបានជានាងយំ ?

ព្រះរាជទេវីពោលថា បពិត្រលោកម្ចាស់ បុត្ររបស់នាងខ្ញុំ ជាអ្នកគួរដល់រាជសម្បត្តិដែលជារបស់ត្រកូល ប្រសិនបើគេនៅក្នុងក្រុងនោះ គេនឹងលើកឡើងនូវស្វេតច្ឆត្រឡើង ឥឡូវនេះ គេកើតជាអ្នកវិនាសធំហើយ ព្រោះសេចក្តីសោកនេះឯង ទើបខ្ញុំយំ ។

តាបសពោលថា ណ្ហើយចុះ ! ម្នាលនាងដ៏ចម្រើន កុំគិតឡើយ បើនាងប្រាថ្នារាជសម្បត្តិឲ្យបុត្រ ខ្ញុំនឹងធ្វើឲ្យគេបានរាជសម្បត្តិ (សមដូចតាមប្រាថ្នា) ។

គ្រានោះ ព្រះតាបសបានឲ្យពិណ និងមន្តដែលញ៉ាំងដំរីឲ្យគាប់ចិត្តដល់បុត្ររបស់ព្រះនាង ។ ក្នុងកាលនោះ ដំរីច្រើនពាន់បានមកប្រជុំគ្នា អង្គុយនៅក្រោមដើមជ្រៃ ។ លំដាប់នោះ តាបសទើបពោលជាមួយកុមារនោះថា កាលដំរីទាំងឡាយមិនទាន់មកដល់ កូនចូរឡើងដើមឈើ កាលដំរីទាំងឡាយមកដល់ហើយ ចូរពាយមន្តបទនេះ ដេញខ្សែពិណនេះ ដំរីទាំងអស់មិនអាចនឹងងាកមកមើល នឹងរត់ចេញទៅ ពេលនោះ កូនគប្បីចុះមក ។ កុមារនោះទ្រង់ធ្វើតាមយ៉ាងនោះ ហើយត្រឡប់មកទូលប្រាប់ការប្រព្រឹត្តទៅនោះឯង ។ លុះថ្ងៃទី

២ តាបសទើបពោលជាមួយកុមារនោះថា ក្នុងថ្ងៃនេះ កូនចូររាយមន្តនេះ ដេញខ្សែពិណនេះ ដំរីនឹងត្រឡប់មើលខាងក្រោយបណ្តើរ រត់ទៅបណ្តើរ ។ សូម្បីកាលនោះ ព្រះកុមារក៏ទ្រង់ធ្វើតាមយ៉ាងនោះ ហើយត្រឡប់មកទូលប្រាប់ការប្រព្រឹត្តទៅនោះទៀត ។ គ្រានោះ តាបសហៅព្រះមាតារបស់កុមារនោះមក ហើយពោលថា ម្នាលនាងដ៏ចម្រើន នាងចូរប្រាប់ដំណឹងដល់បុត្ររបស់នាង គេទៅអំពីទីនេះហើយ នឹងជាស្តេចផែនដី ។ ព្រះទេវីត្រាស់ហៅព្រះឱរសមក ហើយត្រាស់ថា កូនជាឱរសរបស់ព្រះបាទបូរន្តប្បៈក្នុងក្រុងកោសម្ពី បក្សី-ហត្ថិលិង្គ នាំយើងមកខណៈដែលមាតាមានគភ៌ ហើយត្រាស់ប្រាប់ឈ្មោះរបស់សេនាបតីជាដើម និងត្រាស់ថា បើគេមិនជឿ កូនគប្បីសម្តែងព្រះភូសាដណ្តប់ពណ៌ក្រហម និងព្រះទម្រង់ដែលជាគ្រឿងប្រដាប់របស់ព្រះបិតានេះ ទើបឲ្យព្រះកុមារយាងទៅ ។ ព្រះកុមារទើបទូលសួរតាបសថា ឥឡូវនេះ ខ្ញុំនឹងធ្វើអ្វី? តាបសពោលថា កូនចូរអង្គុយស្ទៀមក្រោមដើមឈើ ហើយរាយមន្តបទនេះ ដេញខ្សែពិណនេះ ដំរីដែលជាមេហ្វូងនឹងបង្អោនខ្នងមករកកូន កូនចូរអង្គុយ លើខ្នងមេដំរីនោះ ហើយចូរទៅកាន់យករាជសម្បត្តិចុះ ។ ព្រះកុមារនោះ ថ្វាយបង្គំព្រះរាជបិតាព្រះរាជមាតាហើយ ទ្រង់ក៏ធ្វើតាម បានអង្គុយខាងលើខ្នងដំរីដែលមកហើយ ខ្សឹបដាក់ត្រចៀកដំរីថា ខ្ញុំជាបុត្ររបស់ព្រះបាទបូរន្តប្បៈ ក្នុងក្រុងកោសម្ពី សូមអ្នកចូរយករាជសម្បត្តិដែលជារបស់ព្រះបិតាមកឲ្យដល់ខ្ញុំ ដំរីជាមេហ្វូងស្តាប់ពាក្យនោះហើយ ទើបស្រែកជាសម្លេងដំរីថា ដំរីចូរមកប្រជុំគ្នាច្រើនពាន់ ។ ដំរីច្រើនពាន់មកប្រជុំគ្នាហើយ ។ ស្រែកទៀតថា ដំរីចាស់ៗ ចូរថយទៅក្រោយ ។ ដំរីចាស់ៗ ក៏នាំគ្នាថយក្រោយ ។

ស្រែកទៀតថា ដំរីក្មេងៗ ចូរមក ។ សូម្បីដំរីទាំងនោះក៏នាំគ្នាមកហើយ ។ ព្រះកុមារដែលដំរីចម្បាំងច្រើនពាន់ នាំគ្នាហែហមហើយ មកដល់បច្ចន្តគ្រាម ក៏បានប្រកាសថា យើងជាឱរសរបស់ស្ដេចផែនដី អ្នកដែលប្រាថ្នាសម្បត្តិ ចូរមកជាមួយយើង ។ តាំងអំពីនោះមក ទ្រង់ក៏ធ្វើការរួបរួម មនុស្សទៅលោមព័ទ្ធព្រះនគរ ហើយញ្ញូនដំណឹងទៅថា នឹងឲ្យចម្បាំង ឬនឹងឲ្យរាជសម្បត្តិ ? ពួកអ្នកក្រុងទាំងឡាយពោលថា យើងមិនឲ្យទាំងពីរយ៉ាង ព្រោះថា ព្រះទេវីរបស់ពួកយើងមានព្រះគភ៌ចាស់ ត្រូវសត្វហត្ថិលិង្គនាំយកទៅ យើងទាំងឡាយមិនដឹងថា ព្រះនាងនៅមានព្រះជន្ម ឬថាអស់ព្រះជន្មនៅឡើយ អស់កាលដែលយើងមិនជ្រាបរឿងរាវរបស់ព្រះនាង យើងនឹងមិនឲ្យទាំងការច្បាំងនិងរាជសម្បត្តិ ។ បានឮថា ភាពជាស្ដេចផែនដី ព្រោះការបន្តខ្សែស្រឡាយបានមានហើយក្នុងកាលនោះ ។ លំដាប់នោះ ព្រះកុមារទើបត្រាស់ថា យើងជាបុត្ររបស់ព្រះនាង ហើយរឭកឈ្មោះរបស់សេនាបតីជាដើម ។ កាលជនទាំងនោះមិនជឿ ទើបសម្ដែងសំពត់កម្ពលក្រហម និងព្រះទម្រង់ ។ ពួកអ្នកក្រុងចាំសំពត់កម្ពលក្រហម និងព្រះទម្រុងនោះបាន អស់ការសង្ស័យទើបបើកទ្វារនគរ ហើយអភិសេកព្រះកុមារនោះក្នុងរាជសម្បត្តិ ។

នេះជារឿងនៃព្រះបាទឧតេនជាគ្រាដំបូង ។

# ប្រវត្តិព្រះនាងវាសុលទត្តា

*ព្រះបាទឧទេន មានព្រះរាជទេវីមួយព្រះអង្គទៀត ទ្រង់ព្រះនាមថា ព្រះនាងវាសុលទត្តា ជាព្រះរាជធីតារបស់ព្រះបាទចណ្ឌបជ្ជោត ។ សេចក្ដីពិស្ដារថា ក្នុងក្រុងឧជ្ជេនី មានព្រះរាជាទ្រង់ព្រះនាមថា ព្រះបាទចណ្ឌ-បជ្ជោត ។ ថ្ងៃមួយ ព្រះអង្គស្ដេចមកអំពីព្រះរាជឧទ្យាន ទ្រង់ទតមើលសម្បត្តិរបស់ព្រះអង្គហើយត្រាស់ថា "សម្បត្តិដូច្នេះ របស់បុគ្គលដទៃណាមានឬទេ ហ្ន៎" ។ កាលអាមាត្យក្រាបទូលថា "នេះឈ្មោះថាជាសម្បត្តិអ្វី សម្បត្តិរបស់ព្រះបាទឧទេនក្នុងក្រុងកោសម្ពីច្រើនក្រៃលែង" ដូច្នេះហើយត្រាស់ថា "បើដូច្នោះ យើងនឹងចាប់ព្រះបាទឧទេន" ។*

***អាមាត្យ*** : *នរណាៗ ក៏មិនអាចនឹងចាប់ព្រះរាជាអង្គនោះបានឡើយ ព្រះអង្គ ។*

***ព្រះរាជា*** : *យើងនឹងធ្វើឧបាយ ចាប់ឲ្យបាន ។*

***អាមាត្យ*** : *មិនអាចទេ ព្រះអង្គ ។*

***ព្រះរាជា*** : *ព្រោះហេតុអ្វី ?*

***អាមាត្យ*** : *ព្រោះព្រះបាទឧទេននេះ ចេះសិល្បៈឈ្មោះហត្ថីកន្តៈ ទ្រង់រាយមន្តហើយដេញពិណហត្ថីកន្តៈ នឹងឲ្យដំរីនោះរត់ទៅបាន នឹងចាប់យកក៏បាន អ្នកទៅដោយពាហនៈដំរី ឈ្មោះថា ស្មើដោយព្រះអង្គមិនមាន ។*

*ព្រះរាជា* : យើងមិនអាចចាប់គេបានទេឬ?

*អាមាត្យ* : ព្រះកុរណាព្រះអង្គ ប្រសិនបើព្រះអង្គមានព្រះទ័យបំណង ដូច្នេះ ពិតមែន បើដូច្នោះ សូមព្រះអង្គត្រាស់បង្គាប់ឲ្យជាងធ្វើជាដំរីឈើ ហើយ បញ្ជូនទៅកាន់ទីនៅរបស់ព្រះបាទឧទេននោះ ព្រះរាជាទ្រង់ស្គាប់ រឿង ពាហនៈដំរី ឬពាហនៈសេះហើយ ស្តេចក៏យាងទៅកាន់ទីឆ្ងាយ យើង នឹងអាចចាប់ស្តេចឧទេន ដែលស្តេចមកកាន់ក្នុងទីនោះបាន ។ ព្រះរាជា ត្រាស់ថា "ឧបាយនេះ ប្រើបាន" ដូច្នេះ ទើបត្រាស់បង្គាប់ឲ្យជាងធ្វើដំរីយន្ត សម្រេចដោយឈើយកសំពត់រុំពីខាងក្រៅ ហើយធ្វើជាក្បូរក្បាច់ ឲ្យលែង ទៅត្រង់មាត់ស្រះមួយកន្លែង ក្នុងទីជិតដែនរបស់ព្រះបាទឧទេននោះ ។ បុរស ៦០ នាក់ដើរទៅមកក្នុងពោះដីរីបាន (ដំរីយន្ត) ពួកគេនាំអាចម៍ដំរីមក ចោលទុកក្នុងទីនោះៗ ។ ព្រានព្រៃម្នាក់ឃើញដំរីហើគិតថា "ដំរីនេះគួរដល់ ស្តេចផែនដីរបស់យើង" ដូច្នេះហើយ ទើបទៅក្រាបទូលព្រះបាទឧទេនថា "បពិត្រព្រះអង្គ ខ្ញុំព្រះអង្គជួបដំរីដ៏ប្រសើរមួយក្បាលជាដំរីស មានចំណែក ប្រៀបដោយកំពូលភ្នំកៃលាស គួរដល់ព្រះអង្គតែម្យ៉ាង" ។ ព្រះបាទឧទេន ឲ្យព្រានព្រៃនោះឯងជាអ្នកនាំផ្លូវ ទ្រង់ឡើងសេះព្រមដោយបរិវារ ស្តេច ចេញទៅហើយ ។ ពួកបុរសជ្រាបការដែលមករបស់ស្តេចឧទេន ទើបទៅ ក្រាបទូលព្រះបាទចណ្ឌបជ្ជោត ។ ព្រះបាទចណ្ឌបជ្ជោត ស្តេចមកហើយ បានប្រជុំពលនិកាយទុក ២ ចំណែក ដាក់ដំរីទុកត្រង់កណ្តាល ។ ព្រះបាទ

ឧទេនទ្រង់មិនបានជ្រាបដល់ការមក របស់ព្រះបាទចណ្ឌបជ្ជោត ។ ទើបដេញទៅតាមដំរី ។ មនុស្សដែលនៅខាងក្នុង ក៏ប្រញាប់នាំដំរីឈើរត់ទៅយ៉ាងរហ័ស កាលព្រះរាជាទ្រង់ពាយមន្តដេញពិណ ដំរីធ្វើដូចជាមិនបានឮសម្លេងនៃខ្សែពិណ គឺរត់ទៅតែម្យ៉ាង ។ ព្រះរាជាទ្រង់មិនអាចចាប់ស្តេចដំរីបាន ទើបស្តេចឡើងស្តេចសេះដេញតាមទៅ ។ កាលព្រះបាទឧទេនដេញទៅតាមដោយប្រញាប់យ៉ាងនេះ ពលនិកាយរបស់ព្រះអង្គក៏អស់កម្លាំង ។ នៅតែព្រះរាជាមួយព្រះអង្គឯងប៉ុណ្ណោះ ។ គ្រានោះ ពួកបុរសរបស់ព្រះបាទចណ្ឌបជ្ជោត ដែលស្នាក់ចាំនៅសងខាង (ផ្លូវ) ក៏ចាប់ព្រះបាទឧទេនថ្វាយស្តេចផែនដីរបស់ខ្លួន ។ បន្ទាប់មក ពលនិកាយរបស់ព្រះបាទឧទេនជ្រាបថាព្រះរាជារបស់ខ្លួនធ្លាក់ទៅ ក្នុងអំណាចនៃសត្រូវហើយ ទើបតាំងជំរុំនៅខាងក្រៅ ។

ចំណែកព្រះបាទចណ្ឌបជ្ជោត ទ្រង់បញ្ជាឲ្យចាប់ព្រះបាទឧទេនហើយទ្រង់ត្រាស់ឲ្យយកទៅដាក់ក្នុងគុក ដែលសម្រាប់ដាក់ចោរមួយកន្លែង ឲ្យបិទទ្វារ ទ្រង់ផឹកទឹកជ័យអស់ ៣ ថ្ងៃ ។ ក្នុងថ្ងៃទី ៣ ព្រះបាទឧទេនទ្រង់សួរអ្នកយាមថា នែអ្នកទាំងឡាយ ស្តេចផែនដីរបស់ពួកអ្នកទៅណា ?

**ពួកអ្នកយាម** : ស្តេចផែនដីទ្រង់ផឹកទឹកជ័យព្រោះតែត្រេកអរថា យើងចាប់បច្ចាមិត្របាន ។

**ឧទេន** : ស្ដេចផែនដីរបស់ពួកអ្នកមានកិរិយាអ្វី ដូចជាស្រី ការចាប់ស្ដេចផែនដីដែលជាសត្រូវបានហើយ នឹងលែង ឬសម្លាប់ទើបគួរមិនមែនឬ បែរជាឲ្យយើងអង្គុយទទួលទុក្ខ ហើយទៅផឹកទឹកជ័យទៅវិញ ។

អ្នកយាមនោះ ក៏នាំគ្នាទៅទូលសេចក្ដីនោះដល់ព្រះរាជា ។ ព្រះអង្គស្ដេចទៅ ត្រាស់សួរថា បានឮថា លោកនិយាយយ៉ាងនេះ ពិតឬ ?

**ឧទេន** : ត្រូវហើយ មហារាជ ។

**ចណ្ឌបជ្ជោត** : ល្អហើយ យើងនឹងលែងលោក យើងដឹងថា លោកមានមន្តដូច្នេះ លោកនឹងឲ្យមន្តនោះដល់យើងទេ ?

**ឧទេន** : លែងហើយ ខ្ញុំព្រះអង្គនឹងឲ្យក្នុងវេលារៀន ចូរថ្វាយបង្គំខ្ញុំព្រះអង្គ ហើយរៀនមន្តនោះ តើលោកថ្វាយបង្គំខ្ញុំព្រះអង្គឬទេ ?

**ចណ្ឌបជ្ជោត** : យើងនឹងថ្វាយបង្គំលោកដូចម្ដេច ?

**ឧទេន** : លោកមិនថ្វាយបង្គំឬ ?

**ចណ្ឌបជ្ជោត** : យើងមិនថ្វាយបង្គំទេ ។

**ឧទេន** : សូម្បីខ្ញុំព្រះអង្គ ក៏មិនឲ្យដែរ ។

**ចណ្ឌបជ្ជោត** : បើដូច្នេះ យើងនឹងដាក់អាជ្ញាដល់លោក ។

**ឧទេន** : សូមធ្វើចុះ ព្រោះលោកជាធំលើរាងកាយរបស់ខ្ញុំ តែមិនមែនជាធំលើចិត្តខ្ញុំទេ ។

ព្រះរាជាទ្រង់ស្តាប់ពាក្យដ៏អង់អាច របស់ព្រះបាទឧទេនហើយ ទើបទ្រង់ត្រិះរិះថា "យើងនឹងរៀនមន្តរបស់ស្តេចឧទេននេះបានដូចម្តេចហ្ន៎" ។ ហើយទ្រង់គិតបានថា "យើងមិនអាចឲ្យអ្នកដទៃចេះមន្តនេះទេ យើងនឹងធីតារបស់យើងរៀនក្នុងសម្នាក់ស្តេចឧទេននេះ ហើយទើបរៀនក្នុងសម្នាក់របស់នាង ។ លំដាប់នោះ ព្រះបាទចណ្ឌបជ្ជោតទើបត្រាស់ចំពោះព្រះបាទឧទេននោះថា "លោកនឹងបង្រៀនដល់មនុស្សដទៃដែលថ្វាយបង្គំលោកឬ?

**ឧទេន** : យ៉ាងនោះឯង មហារាជ ។

**ចណ្ឌបជ្ជោត** : បើដូច្នោះ ក្នុងផ្ទះរបស់យើងមានស្រីគមម្នាក់ នាងឈរនៅខាងក្រៅវាំងនន ចូរប្រាប់មន្តដល់ស្រីនោះ ដែលអង្គុយនៅខាងក្នុងវាំងននោះចុះ ។

**ឧទេន** : ល្អហើយ មហារាជ នាងជាមនុស្សគមឬ មនុស្សគមក៏ដោយ ចុះកាលនាងថ្វាយបង្គំ ខ្ញុំព្រះអង្គនឹងបង្រៀន ។

លំដាប់នោះ ព្រះរាជាស្តេចយាងទៅត្រាស់ប្រាប់ព្រះនាងវាសុលទត្តារាជធីតាថា "ម្នាលកូនស្រី បុរសមានរោគឃ្លង់ម្នាក់ ចេះមន្តកាត់ថ្លៃមិនបាន ពុកមិនអាចឲ្យអ្នកដទៃចេះមន្តនោះទេ កូនអង្គុយនៅខាងក្នុងវាំងននថ្វាយ

*បង្គំបុរសនោះហើយរៀនមន្ត បុរសនោះឈរនៅខាងក្រៅវាំងននទឹងបង្រៀន (មន្ត) ដល់កូន បិតានឹងរៀនពីបុត្រ" ។ ស្តេចចណ្ឌបជ្ជោតត្រាស់ធ្វើព្រះរាជធីតាថាជាស្រីគម ចំណែកព្រះបាទឧទេនថាជាបុរសកើតឃ្លង់ ដូច្នេះ ព្រោះទ្រង់ខ្លាចអ្នកទាំងពីរនោះនឹងធ្វើសន្ថវៈដល់គ្នានឹងគ្នា ។ ព្រះបាទឧទេនប្រថាប់ឈរនៅខាងក្រៅវាំងនន បានបង្រៀនមន្តដល់ព្រះនាងដែលបានថ្វាយបង្គំហើយ អង្គុយខាងក្នុងវាំងនន ។*

*តមកថ្ងៃមួយ ព្រះបាទឧទេនត្រាស់នឹងព្រះនាង សូម្បីស្តេចត្រាស់ប្រាប់រឿយៗ ក៏ព្រះនាងមិនអាចនឹងពោលបទនៃមន្តបាន ទើបទ្រង់ត្រាស់ថា "នៃស្រីគម ! បបូរមាត់របស់នាងឯងក្រាស់ណាស់ឬ នាងឯងចូរពោលយ៉ាងនេះ" ។ ព្រះនាងទ្រង់ខ្ញាល់ ទើបត្រាស់ថា "យើ ! អាគម្លង់ មានជាតិអាក្រក់ឯងនិយាយអ្វី មនុស្សដូចយើងជាស្រីគមឬ" ដូច្នេះ ហើយទ្រង់បើកវាំងននឡើង កាលព្រះបាទឧទេនត្រាស់សួរថា "នាងជានរណា" ទើបត្រាស់ប្រាប់ថា "យើងឈ្មោះវាសុលទត្តា ធីតារបស់ស្តេចផែនដី" ។*

***ព្រះបាទឧទេន*** : *បិតារបស់នាង កាលត្រាស់ដល់យើង បានត្រាស់ប្រាប់ថា "នាងស្រីគម" ។*

***វាសុលទត្តា*** : *សូម្បីទ្រង់ត្រាស់ដល់ខ្ញុំ ព្រះបិតាក៏ទ្រង់ត្រាស់ថាលោកជាបុរសឃ្លង់ ។*

ទាំងពីរព្រះអង្គនោះ ទ្រង់ត្រិះរិះថា "ព្រះរាជាទ្រង់ត្រាស់ពាក្យនោះ ព្រោះខ្លាចយើងធ្វើសន្ថវៈនឹងគ្នា ។ ហើយទ្រង់ធ្វើសន្ថវៈជាមួយគ្នាខាងក្នុងរាំងននោះឯង ។ តាំងអំពីនោះមក ការរៀនមន្ត ឬការរៀនសិល្បៈទើបមិនមាន ។ ចំណែកព្រះរាជាទ្រង់សួរព្រះធីតាជារឿយៗ ថា បុត្ររៀនសិល្បៈយូរទៀតឬ ។ ព្រះនាងត្រាស់ថា "បពិត្រព្រះបិតា ខ្ញុំម្ចាស់នៅរៀនទៀត" ។ តមកថ្ងៃមួយ ព្រះបាទឧទេនត្រាស់នឹងព្រះនាងថា "នាងដ៏ចម្រើនឈ្មោះថា នាទីដែលស្វាមីគប្បីធ្វើ មាតាបិតា បងប្អូនប្រុស និងបងប្អូនស្រីមិនអាចធ្វើបានឡើយ ប្រសិនបើនាងឲ្យជីវិតដល់យើង យើងនឹងស្រី ៥០០ នាក់ជា បរិវារ ហើយនឹងឲ្យតំណែងជាអគ្គមហេសីដល់នាង" ។ ព្រះនាងត្រាស់ថា "បើព្រះអង្គតាំងនៅក្នុងព្រះតម្រាស់នេះ ខ្ញុំម្ចាស់ក៏នឹងថ្វាយជីវិតទាននេះដល់ព្រះអង្គ" ។ ព្រះបាទឧទេនត្រាស់តបថា "ម្នាលនាងដ៏ចម្រើន យើងអាច" ព្រះនាងទ្រង់ទទួលព្រះតម្រាស់ថា "យល់ព្រម" ដូច្នេះ ហើយក៏ស្ដេចទៅ កាន់សំណាក់របស់ព្រះរាជបិតា ថ្វាយបង្គំហើយ បានឈរនៅក្នុងទីដ៏សមគួរ មួយ ។ លំដាប់នោះ ព្រះរាជាត្រាស់សួរព្រះនាងថា សិល្បៈសម្រេចហើយឬ បុត្រី ?

**វាសុលទត្តា** : បពិត្រព្រះបិតា សិល្បៈនៅមិនទាន់សម្រេចទេ ។

លំដាប់នោះ ព្រះបាទចណ្ឌបជ្ជោតត្រាស់សួរព្រះនាងថា ហេតុអ្វី បុត្រី?

**វាសុលទត្តា** : បពិត្រព្រះបិតា នាងខ្ញុំគួរនឹងបានទ្វារណាមួយ (សិទ្ធពិសេសក្នុងការចូលចេញ) ជាមួយពាហនៈមួយក្បាល ។

*ចណ្ឌបជ្ជោត* : *ហេតុអ្វី កូនស្រី ។*

*វាសុលទត្តា* : *បពិត្រព្រះបិតា ព្រោះថាមានឱសថមួយប្រភេទត្រូវរក្សាក្នុងវេលាយប់ ដោយសញ្ញាតាមផ្កាយ ដើម្បីជាប្រយោជន៍ឧបការៈដល់ការរៀនមន្ត ព្រោះដូច្នោះ ក្នុងវេលាដែលខ្ញុំម្ចាស់ចេញទៅក្នុងវេលា ឬខុសវេលាទើបគួរនឹងបានទ្វារណាមួយ ជាមួយពាហនៈមួយក្បាល ។*

*ព្រះរាជាត្រាស់ថា "បាន" ។*

*ព្រះឧទេន និងព្រះនាងវាសុលទត្តា ទ្រង់បានកាន់យកទ្វារមួយដែលខ្លួនពេញចិត្តទុកក្នុងដៃរបស់ខ្លួន ។*

*ឯព្រះរាជាមានពាហនៈ ៥ គឺ ដំរីញី ១ ឈ្មោះភទ្ទវតី ដើរមួយថ្ងៃបាន ៥០ យោជន៍, ទាសៈឈ្មោះកាកៈ ដើរមួយថ្ងៃបាន ៦០ យោជន៍, សេះ ២ ក្បាល គឺសេះចេលកណ្ឋិ និងសេះមុញ្ចកេសី ដើរមួយថ្ងៃបាន ១០០ យោជន៍, ដំរីនាឡាគិរីដើរមួយថ្ងៃបាន ១២០ យោជន៍ ។*

*បានឮមកថា ព្រះរាជាអង្គនោះ ក្នុងកាលព្រះពុទ្ធទ្រង់មិនទាន់ឧប្បត្តិឡើង ទ្រង់ជាអ្នកបម្រើរបស់ឥស្សរជនម្នាក់ ។ ថ្ងៃមួយ កាលឥស្សរជននោះចេញទៅក្រៅព្រះនគរ ងូតទឹកហើយត្រឡប់មក ព្រះបច្ចេកពុទ្ធមួយព្រះអង្គចូលកាន់ព្រះនគរដើម្បីបិណ្ឌបាត មិនបានភិក្ខាសូម្បីត្រឹមតែបន្តិចព្រោះពួកអ្នកស្រុកទាំងអស់ត្រូវមារបណ្តាលចិត្ត មានបាត្រដូចជាលាងទុក*

ហើយ (បាត្រ) ទ្រង់ក៏និមន្តចេញទៅ ។ លំដាប់នោះ មារចូលទៅរកព្រះបច្ចេកពុទ្ធ ដោយភេទដែលមិនមាននរណាស្គាល់ ហើយសួរលោកក្នុងខណៈដែលលោកនិមន្តដល់ទ្វារព្រះនគរថា "លោកម្ចាស់ លោកបានអ្វីខ្លះទេ"? ព្រះបច្ចេកពុទ្ធតបថា "អ្នក ជាអ្នកធ្វើឲ្យយើងមិនបានអ្វីមិនមែនឬ?"

**មារ** : បើដូច្នោះ សូមលោកម្ចាស់ចូរនិមន្តត្រឡប់ទៅវិញម្តងទៀតចុះ ខ្ញុំព្រះអង្គមិនធ្វើទៀតទេ ។

**ព្រះបច្ចេកពុទ្ធ** : យើងមិនត្រឡប់ទៅវិញទៀតទេ ។

ប្រសិនបើព្រះបច្ចេកពុទ្ធ ព្រះអង្គគប្បីនិមន្តត្រឡប់ទៅវិញ មារនោះនឹងបណ្តាលអ្នកស្រុកទាំងអស់នោះ ឲ្យទះដៃសើចចំអកដល់ព្រះអង្គ កាលព្រះបច្ចេកពុទ្ធមិននិមន្តចូលទៅ មារក៏វបាត់ទៅក្នុងពេលនោះឯង ។ ខណៈនោះ ឥស្សរជននោះ គ្រាន់តែឃើញព្រះបច្ចេកពុទ្ធទ្រង់និមន្តមកហើយដោយបាត្រទទេ ទើបថ្វាយបង្គំ ហើយសួរថា "បពិត្រលោកម្ចាស់ លោកម្ចាស់បានអ្វីខ្លះទេ? លោកឆ្លើយថា "អ្នកមានអាយុ អាត្មានិមន្តទៅហើយ ហើយនិមន្តមកវិញ" ។ គេគិតថា "លោកម្ចាស់មិនឆ្លើយតបមានពាក្យដែលយើងសួរ ត្រឡប់ជាឆ្លើយពាក្យដទៃវិញ លោកប្រាកដជានៅមិនទាន់បានអ្វីៗក្នុងរំពេចនោះ គេក្រឡេកមើលបាត្ររបស់លោក ឃើញបាត្រទទេក៏ជាអ្នកក្បៀវក្លា (មានសទ្ធា) តែមិនអាចទទួលបាត្រ ព្រោះនៅមិនទាន់ដឹងថា ភត្តក្នុងផ្ទះរបស់ខ្លួនសម្រេចហើយ ឬនៅមិនទាន់សម្រេច ទើបពោលថា "លោក

ម្ចាស់ សូមលោកម្ចាស់រង់ចាំបន្តិច " ដូច្នេះ ក៏ប្រញាប់រត់ទៅផ្ទះ សួរថា "ភត្ត សម្រាប់យើងមានហើយឬ" កាលអ្នកបម្រើប្រាប់ថា "មានហើយ" ទើបពោល នឹងអ្នកបម្រើនោះថា "នែបា! អ្នកដទៃដែលរហ័សជាងអ្នករមែងមិនមាន ដោយសន្ទុះដើងដ៏រហ័ស អ្នកចូរទៅឲ្យដល់លោកម្ចាស់ឯណោះ ពោលថា លោកម្ចាស់ សូមលោកម្ចាស់ចូរឲ្យបាត្រ ហើយទទួលបាត្រមកឲ្យរហ័ស" ។ គេក៏រត់ទៅតាមពាក្យដែលប្រាប់នោះ ត្រឹមតែមួយម៉ាត់ប៉ុណ្ណោះ ទទួលបាត្រ នាំមកហើយ ។ សូម្បីឥស្សរជន ក៏ធ្វើបាត្រឲ្យពេញដោយភោជនរបស់ខ្លួន ហើយពោលថា "អ្នកចូរប្រញាប់ទៅ ថ្វាយបាត្រនេះដល់លោកម្ចាស់ យើង នឹងចែកចំណែកបុណ្យដែលកើតពីទាននេះដល់អ្នក" ។ គេទទួលបាត្រនោះ ហើយ ទៅដោយដើងយ៉ាងរហ័ស ថ្វាយបាត្រដល់ព្រះបច្ចេកពុទ្ធ ថ្វាយបង្គំ ដោយបញ្ចង្គប្រតិស្ឋាន ហើយពោលថា "បពិត្រលោកម្ចាស់ វេលាដ៏ប្រញាប់ យ៉ាងនេះ ខ្ញុំព្រះអង្គទៅមកដោយសន្ទុះដើងក៏រហ័ស ដោយផលនៃសន្ទុះ ដើងដ៏រហ័សរបស់ខ្ញុំនេះ សូមពាហនៈទាំងឡាយ ៥ ដែលនឹងអាចទៅបាន មួយថ្ងៃ ៥០ យោជន៍ ៦០ យោជន៍ ១០០ យោជន៍ ១២០ យោជន៍ ចូរកើត ឡើងដល់ខ្ញុំព្រះអង្គ ម្យ៉ាងទៀត រាងកាយរបស់ខ្ញុំព្រះអង្គដែលមក និងទៅ ត្រូវកម្តៅព្រះអាទិត្យហើយ ដោយផលនៃការត្រូវកម្តៅព្រះអាទិត្យនោះ សូម ឲ្យខ្ញុំព្រះអង្គ មានតេជៈផ្សាយទៅដូចជាពន្លឺព្រះអាទិត្យ ក្នុងទីដែលបានកើត ហើយ ចំណែកបុណ្យព្រោះបិណ្ឌបាតនេះ ដែលចៅហ្វាយនាយឲ្យហើយ

ដល់ខ្ញុំ ដោយផលដែលហូរចេញអំពីចំណែកបុណ្យនោះ សូមឲ្យខ្ញុំព្រះអង្គចូរជាអ្នកមានចំណែកនៃធម៌ដែលលោកម្ចាស់ឃើញហើយ" ។ ព្រះបច្ចេក-ពុទ្ធពោលថា "សូមសេចក្ដីប្រាថ្នាដែលអ្នកតាំងទុកនេះ ចូរសម្រេច" ហើយ មានធ្វើអនុមោទនាថា៖

**វត្ថុដែលអ្នកត្រូវការហើយ ប្រាថ្នាហើយ ចូរសម្រេច ដោយឆាប់រួសរាន់ដល់អ្នក សូមតម្រិះទាំងពួងចូរពេញ ដូចព្រះចន្ទដែលមានក្នុងតិថីទី ១៥ កើត ។**

**វត្ថុដែលអ្នកត្រូវការហើយ ប្រាថ្នាហើយ ចូរសម្រេចដោយឆាប់រួសរាន់ដល់អ្នក សូមតម្រិះទាំងពួងចូរចេញដូចកែវមណីឈ្មោះជោតិរស ។**

បានជ្រាបថា គាថា ២ គាថានេះឯង ឈ្មោះថា គាថាអនុមោទនារបស់ព្រះបច្ចេកពុទ្ធទាំងឡាយ ។ រតនៈ គឺ កែវមណី ដែលឲ្យសម្រេចនូវវត្ថុតាមប្រាថ្នាទាំងពួង ហៅថា "កែវមណីជោតិរស" ក្នុងគាថានោះ ។ នេះជាបុព្វចរិយានៃបុរសអ្នកបម្រើនោះ ។ គេបានជាស្ដេចចណ្ឌបជ្ជោតក្នុងកាលឥឡូវនេះ ។ម្យ៉ាងទៀត ព្រោះផលដែលហូរចេញនៃកម្មនោះ ពាហនៈទាំង ៥ នេះទើបកើតឡើង ។

តមកថ្ងៃមួយ ព្រះរាជាស្ដេចទៅដើម្បីត្រាច់កម្សាន្តក្នុងព្រះរាជឧទ្យាន ព្រះបាទឧទេនទ្រង់ត្រិះរិះថា យើងគប្បីនឹងរត់ចេញទៅក្នុងថ្ងៃនេះ ទើបទ្រង់ដាក់ថង់ស្បែកធំៗ ឲ្យពេញដោយមាស និងប្រាក់ដលើខ្នងសេះ ហើយនាំ

ព្រះនាងវាសុលទត្តាចេញទៅ ។ ទាហានរក្សាវាំងទាំងឡាយឃើញព្រះបាទឧទេនរត់ចេញទៅ ទើបក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាទ្រង់បញ្ជូនពលទៅដោយព្រះតម្រាស់បញ្ជាថា "ពួកអ្នក ចូរដេញតាមឲ្យលឿន" ។ ព្រះបាទឧទេនទ្រង់ដឹងថាពលនិកាយដេញតាម ទើបទ្រង់ស្រាយថង់កហាបណៈធ្វើកហាបណៈឲ្យធ្លាក់ (រាយប៉ាយ) ។ ពួកពលនិកាយក៏នាំគ្នាឈប់រើសកហាបណៈ ហើយទើបដេញតាមទៀត ។ ចំណែកព្រះបាទឧទេន ក៏ស្រាយថង់មាសហើយធ្វើឲ្យធ្លាក់ទៀត កាលពលនិកាយទាំងនោះមានដំណើរយឺតយូរ ព្រោះល្មោភក្នុងមាស ស្ដេចក៏យាងដល់ជំរុំរបស់ព្រះអង្គដែលតាំងនៅខាងក្រៅ ។ ខណៈនោះ ពលនិកាយកាលបានឃើញព្រះរាជារបស់ខ្លួនមកក៏ហែហមស្ដេចឲ្យយាងចូលកាន់កាន់ព្រះនគររបស់ខ្លួនវិញ ។ លុះព្រះរាជាស្ដេចយាងដល់ហើយ ក៏អភិសេកព្រះនាងវាសុលទត្តា តាំងទុកក្នុងតំណែងជាអគ្គមហេសី ។

នេះជារឿងរបស់ព្រះនាងវាសុទត្តា ។